**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

THE GARMENT MANUFACTURERS ASSOCIATION IN CAMBODIA (GMAC)

THE SECRETARIAT

IN No :...918...

Date: 27.08.14 Time: 8:30

For :...GMAC...

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ ...២០៣... ក.ប/ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០១៤

# ប្រកាស

## ស្តីពី

## ការតែងតាំងសមាសភាពគណៈកម្មការប្រឹក្សាគម្រោង នៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងសេចក្តីថ្លែងការអំពីបំណងប្រាថ្នាចង់ឱ្យប្រាកដថា លក្ខខណ្ឌការងារនៅក្នុងវិស័យវាយនភណ្ឌ និងសម្លៀកបំពាក់នៅកម្ពុជា ស្របតាមបទដ្ឋានការងារសំខាន់ៗដែលទទួលស្គាល់ជាអន្តរជាតិ និងច្បាប់ស្តីពីការងារកម្ពុជា ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០០
- យោងអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងពាណិជ្ជកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងអង្គការអន្តរជាតិខាងការងារ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣
- យោងប្រកាសលេខ ២៤៥ ក.ប/ប្រ.ក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មការប្រឹក្សាគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា
- យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពគណៈកម្មការប្រឹក្សាគម្រោង នៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖



*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*

**១-សមាជិកពេញសិទ្ធិ**

ក-តំណាងរាជរដ្ឋាភិបាល

| | | |
|---|---|---|
| ១- ឯកឧត្តម | **ម៉ម វណ្ណៈ** | រដ្ឋលេខាធិការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ២- ឯកឧត្តម | **សេង សក្តា** | អគ្គនាយកការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៣- ឯកឧត្តម | **សុខ សុភ័ក្រ** | អគ្គនាយកសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។ |

ខ-តំណាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា

| | | |
|---|---|---|
| ១- លោកស្រី | **វ៉ាន់ ប៉ោហ្វីន** | សមាជិកប្រតិបត្តិ នៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| ២- លោក | **វ៉េម៉ុន តាំ** | សមាជិកប្រតិបត្តិ នៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| ៣- លោក | **ខេន លូ** | អគ្គលេខាធិការ នៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា។ |

គ-តំណាងចលនាសហជីពកម្ពុជា

| | | |
|---|---|---|
| ១- លោក | **អាត់ ធន់** | ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ២- លោកស្រី | **ទេព គីមវណ្ណារី** | ប្រធានសហព័ន្ធសហជីពឯករាជ្យកម្ពុជា |
| ៣- លោក | **រ័ត្ន មីនា** | ប្រធានសហព័ន្ធសហជីពជាតិ នៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា។ |

**២-សមាជិកបម្រុង**

ក-តំណាងរាជរដ្ឋាភិបាល

| | | |
|---|---|---|
| ១- លោក | **ម៉ក់ ឧសភា** | អគ្គនាយករងសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម |
| ២- លោក | **អ៊ុក ចាន់ធូ** | ប្រធាននាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៣- លោក | **ឡេង តុង** | ប្រធាននាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ |

ខ-តំណាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា

| | | |
|---|---|---|
| ១- លោក | **ការ៉ាំង ម៉ូនីកា** | អគ្គលេខាធិការរង នៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| ២- លោក | **សោម ចំណាន** | ប្រធានផ្នែកច្បាប់និងការងារ នៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| ៣- លោក | **ជាតិ ខេមរា** | មន្ត្រីជាន់ខ្ពស់ផ្នែកការងារ នៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា។ |

គ-តំណាងចលនាសហជីពកម្ពុជា

| | | |
|---|---|---|
| ១- លោក | **នួន ចន្ថា** | អគ្គលេខាធិការសភាសម្ព័ន្ធសហជីពជាតិកម្ពុជា |
| ២- លោក | **យឹង ឈុន** | ប្រធានសហព័ន្ធសហជីពជាតិកម្ពុជា |
| ៣- លោកស្រី | **យ៉ាង សុភ័ណ្ឌ** | ប្រធានសហភាពសហជីពជាតិកម្ពុជា។ |

**ប្រការ២**.-

សមាជិកគណៈកម្មការប្រឹក្សាគម្រោង ដែលតំណាងឱ្យរាជរដ្ឋាភិបាល និងតំណាងឱ្យសមាគមរោងចក្រកាត់ដេរនៅកម្ពុជាមានអាណត្តិពីរឆ្នាំ។ ដោយឡែក សមាជិកគណៈកម្មការប្រឹក្សាគម្រោងដែលតំណាងឱ្យចលនាសហជីពកម្ពុជាមានអាណត្តិប្រាំមួយខែ។

**ប្រការ៣.-**

គណៈកម្មការប្រឹក្សាគម្រោងមានសហប្រធានពីររូប គឺមួយរូបជាសហប្រធានអចិន្ត្រៃយ៍ និងមួយរូបទៀតជាសហប្រធានប្តូរវេន។ សហប្រធានអចិន្ត្រៃយ៍ ត្រូវជ្រើសរើសក្នុងចំណោមសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាគម្រោងដែលតំណាងឱ្យរាជរដ្ឋាភិបាល។ សហប្រធានប្តូរវេន ត្រូវជ្រើសរើសក្នុងចំណោមសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាគម្រោង ដែលតំណាងឱ្យសមាគមរោងចក្រកាត់ដេរនៅកម្ពុជាសម្រាប់រយៈពេលប្រាំមួយខែដំបូង និងត្រូវជ្រើសរើសក្នុងចំណោមសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាគម្រោង ដែលតំណាងឱ្យចលនាសហជីពកម្ពុជា សម្រាប់រយៈពេលប្រាំមួយខែបន្ទាប់។ ការជ្រើសរើសសហប្រធានប្តូរវេន ត្រូវអនុវត្តតាមនីតិវិធីនេះសម្រាប់រយៈពេលប្រាំមួយខែបន្តបន្ទាប់ទៀត។

**ប្រការ៤.-**

ឯកឧត្តម **ម៉ម វណ្ណៈ** ត្រូវបានតែងតាំងជាសហប្រធានអចិន្ត្រៃយ៍ហើយលោកស្រី **ទ៉ាន់ ប៉ោហ្វីន** តំណាងឱ្យសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ត្រូវបានតែងតាំងជាសហប្រធានប្តូរវេនក្នុងរយៈពេលប្រាំមួយខែដំបូង។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គាធិការនៃអគ្គាធិការដ្ឋាន មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត គ្រប់អង្គភាពក្រោមឱវាទក្រសួង និងឯកឧត្តម លោក លោកស្រី ដូចមានក្នុងប្រការ ១ និងប្រការ ៤ មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យ**សម្តេចតេជោនាយករដ្ឋមន្ត្រី**

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ

-ក្រសួងពាណិជ្ជកម្ម

-សមាគមរោងចក្រកាត់ដេរនៅកម្ពុជា

-ប្រធានទីប្រឹក្សាបច្ចេកទេសគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា

-ប្រធានគម្រោងអប់រំដល់ចលនាសហជីពកម្មករកម្ពុជា

-ក្រុមការងារអន្តរជាតិវិស័យការងារ

"ដើម្បីជូនជ្រាប"

-ដូចប្រការ ៥

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ